**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jan-2013, 13:52
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីសម្បទាក្នុងការចូលរួមសវនាការ**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASIINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Florence MUMBA
ចៅក្រម យ៉ា ណារិន

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ**
អៀង សារី

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក អាង ឧត្ដម
លោក Michael G.KARNAVAS

# I. សេចក្តីផ្តើម

១- នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៣ មេធាវីការពារក្តី អៀង សារី ("មេធាវីការពារក្តី") បានដាក់បណ្តឹងសាទុក្ខភ្លាម ("បណ្តឹងសាទុក្ខ") ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យ៖ (i) បញ្ជាក់ឡើងវិញអំពីសេចក្តីសម្រេចមុនៗរបស់ខ្លួនស្តីពីសម្បទាក្នុងការចូលរួមសវនាការរបស់ អៀង សារី ("ជនជាប់ចោទ"), (ii) បដិសេធសំណើរបស់មេធាវីការពារក្តីសុំឲ្យចាត់តាំងអ្នកជំនាញថ្មីមួយរូប, (iii) ច្រានចោលសំណើរបស់មេធាវីការពារក្តីសុំថតវីឌីអូជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ឬផ្តល់គ្រែពេទ្យនៅក្នុងបន្ទប់សវនាការ និង (iv) ការកំណត់ឲ្យផ្អាកកិច្ចដំណើរការនីតិវិធី លើកពេល ឬបំបែកសំណុំរឿងជនជាប់ចោទ ដើម្បីឲ្យមានការធ្វើតេស្ត ឬព្យាបាលសុខភាពបន្ថែម គឺជាការរំលោភដោយគ្មានមូលហេតុទៅលើសិទ្ធិរបស់ជនជាប់ចោទទាំងអស់ ក្នុងសំណុំរឿង០០២ ក្នុងការទទួលបាននូវសវនាការមួយដែលត្រឹមត្រូវ និងឆាប់រហ័ស("សេចក្តីសម្រេចដែលរងការជំទាស់")[1]។ បណ្តឹងសាទុក្ខនេះមិនពាក់ព័ន្ធនឹងបញ្ហានៃការថតវីឌីអូទេ ដែលបញ្ហានោះមេធាវីការពារក្តីបានលើក នៅក្នុងបណ្តឹងសាទុក្ខមួយដោយឡែក[2]។ មេធាវីការពារក្តីពេលនេះស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") មោឃៈសេចក្តីសម្រេចដែលរងការជំទាស់ និងបង្គាប់ទៅអង្គជំនុំជម្រះសាលាដំបូង និងចាត់តាំងអ្នកជំនាញបន្ថែម ដើម្បីវាយតម្លៃលើសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ[3]។

២- មេធាវីការពារក្តីអះអាងដោយពឹងផ្អែកទៅលើវិធាន១០៤(៤)(ខ) និង១០៤(៤)(ឃ) ជាទង្វើករណ៍សម្រាប់ឲ្យទទួលយកបណ្តឹងសាទុក្ខនេះ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងសាទុក្ខនេះគឺមិនអាចឲ្យទទួលយកបានទេ ក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ ដោយផ្អែកលើមូលដ្ឋាននេះ ដើម្បីជាផលប្រយោជន៍ការសន្សំសំចៃរបស់តុលាការ និងដោយគ្មានខ្លឹមសារ សហព្រះរាជអាជ្ញានឹងកំហិតសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួន ត្រឹមតែបញ្ហានៃភាពទទួលយកបានប៉ុណ្ណោះ។

---

[1] **E238/9/2/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសនាការ និងការបដិសេធរបស់អង្គជំនុំជម្រះក្នុងការតែងតាំងអ្នកជំនាញបន្ថែម ដើម្បីវាយតម្លៃសម្បទារបស់គាត់, ៣ មករា ២០១៣ ("បណ្តឹងសាទុក្ខ")។

[2] **E238/9/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឲ្យគាត់ថតជាវីដេអូនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ, ១៨ ធ្នូ ២០១២ ("បណ្តឹងសាទុក្ខបច្ចុប្បន្ន")។

[3] **E238/9/2/1** *កំណត់សម្គាល់លេខ១* ត្រង់ផ្នែកទី VI។

## II. ប្រវត្តិនីតិវិធី

៣- ជនជាប់ចោទពេលនេះមានអាយុ៨៧ឆ្នាំហើយ ហើយបានទទួលការពិនិត្យវេជ្ជសាស្ត្រជាលើកដំបូងតាមដំណើរការរបស់ អ.វ.ត.ក នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧។ នៅពេលនោះ គាត់ត្រូវបានធ្វើរោគវិនិច្ឆ័យទៅលើរោគសញ្ញាខាងផ្លូវកាយមួយចំនួន ដូចជា រលាកសន្លាក់ឆ្អឹងកងខ្នងផ្នែកខាងក្រោម ភាពមិនប្រក្រតីខាងប្រព័ន្ធផ្លោកនោម និងភាពរអាក់រអួលប្រព័ន្ធសសៃឈាមបេះដូង[4]។ ខណៈដែលស្ថានភាពរបស់គាត់កាលពីពេលនោះមានភាពនឹងនរ គេបានធ្វើការកត់សម្គាល់ថា ការណ៍នេះអាចនឹងប្រែប្រួលក្នុងពេលណាមួយ។ ដូច្នេះ ជនជាប់ចោទត្រូវបានដាក់ឲ្យស្ថិតក្រោម "ការតាមដានយ៉ាងជិតដល់"[5] ដែលបានបន្តរហូតតាំងពីពេលនោះមក។

៤- បន្ទាប់ពីមានសំណើរបស់មេធាវីការពារក្តីដែលសុំឲ្យធ្វើការជំនុំជម្រះតែកន្លះថ្ងៃ ដោយសារតែមូលហេតុសុខភាពរបស់ជនជាប់ចោទ[6] អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងសាស្ត្រាចារ្យ John Campbell ដែលជាអ្នកជំនាញអន្តរជាតិខាងថែទាំមនុស្សចាស់ ដើម្បីពិនិត្យ អៀង សារី។ បន្ទាប់ពីការពិនិត្យដែលបានធ្វើឡើងនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១១ សាស្ត្រាចារ្យ Campbell បានរកឃើញថា ខណៈដែលជនជាប់ចោទទទួលរងជម្ងឺស្ទះសសៃឈាមក្នុងបេះដូង ជម្ងឺឈឺខ្នងកាន់តែចុះខ្សោយ និងភាពញឹកញាប់នៃការបត់ជើងតូចកម្រិតពីរ ដែលនាំទៅដល់ការរាំងស្ទះក្រពេញប្រូស្តាត ប៉ុន្តែគាត់មិនមានភាពអន់ថយខាងការចងចាំ ឬការយល់ដឹងទេ[7]។ មេធាវីការពារក្តីមិនបានតវ៉ាអំពីការរកឃើញទាំងនេះឡើយ[8]។

៥- នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ វេជ្ជ. លឹម ស៊ីវុត្ថា ជាវេជ្ជបណ្ឌិតមួយរូបដែលព្យាបាលជនជាប់ចោទ ត្រូវបានអញ្ជើញមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីរាយការណ៍អំពីលទ្ធភាពរបស់

[4] **A100/5** របាយការណ៍វេជ្ជសាស្ត្រ, ១៨ មករា ២០០៨ ត្រង់ទំព័រ១-៣។

[5] **B15/1** របាយការណ៍របស់ជនជាប់ចោទ, ៩ តុលា ២០០៨ ត្រង់ទំព័រ៤-៥។

[6] **E20** ញត្តិរបស់ អៀង សារី សុំដំណើរការសវនាការជំនុំជម្រះក្នុងរយៈពេលកន្លះថ្ងៃ, ១៩ មករា ២០១១។

[7] **E62/3/5** របាយការណ៍អ្នកជំនាញថែទាំមនុស្សចាស់ លោក អៀង សារី ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១១ រៀបចំឡើងជាការឆ្លើយតបទៅនឹងដីការចាត់តាំងជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង, ១៣ មិថុនា ២០១១។

[8] **E110** ដីកាកំណត់កាលបរិច្ឆេទសវនាការ ស្តីពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ, ១២ សីហា ២០១១, ទំព័រ២។

ជនជាប់ចោទក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[9]។ គាត់បានផ្តល់អនុសាសន៍ឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធី តាមមធ្យោបាយចក្ខុទស្សន៍/សោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាកន្លែងដែលវេជ្ជបណ្ឌិតព្យាបាលអាចតាមដានស្ថានភាពសុខភាពរបស់គាត់[10]។

៦- អៀង សារី ត្រូវបានពិនិត្យជាថ្មីម្តងទៀតដោយសាស្ត្រាចារ្យ Campbell និងអ្នកជំនាញពីររូបទៀត កាលពីចុងខែសីហា ឆ្នាំ២០១២។ នៅក្នុងរបាយការណ៍របស់ពួកគាត់ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ អ្នកជំនាញបានបញ្ជាក់អះអាងថា ជនជាប់ចោទនៅតែមានសម្បទាទាំងខាងរាងកាយ និងស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ[11]។

៧- នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ អៀង សារី បានចូលសម្រាកនៅមន្ទីរពេទ្យដោយលើកឡើងអំពីបញ្ហាហេវហត់អស់កម្លាំង ទន់ខ្សោយ និងដង្ហើមខ្លី[12]។ អៀង សារី សម្រាកនៅមន្ទីរពេទ្យអស់រយៈពេលប្រហែលពីរខែ។

៨- នៅថ្ងៃទី៥ និងទី៦ ខែវិច្ឆិកា ឆ្នាំ២០១២ ជនជាប់ចោទបានទទួលការពិនិត្យសុខភាពជាលើកទីបី ដោយសាស្ត្រាចារ្យ Campbell ហើយបានពិនិត្យឃើញមានរោគសញ្ញានៃជម្ងឺវិលមុខភ្លាមក្នុងកម្រិតស្រាល ដោយសារជំហរ ឬចលនា ដែលជាបញ្ហាកើតនៅត្រង់ផ្នែកកណ្តាលរង្វង់ខាងក្នុងនៃរន្ធត្រចៀក[13]។ សាស្ត្រាចារ្យ Campbell បានផ្តល់អនុសាសន៍ថា ការសម្រាកនៅក្នុងមន្ទីរពេទ្យលែងជាការចាំបាច់ទៀតហើយ ប៉ុន្តែបានឱ្យជនជាប់ចោទប្រើឧបករណ៍សម្រួលឱ្យបានពេញលេញដែលមានស្រាប់ក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ព្រមទាំងឱ្យសម្របខ្លួន[14] ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[15]។

---

[9] **E197** លិខិត, កម្មវត្ថុ: "លិខិតអញ្ជើញជូនចំពោះលោកវេជ្ជបណ្ឌិត លឹម ស៊ីវុតថា ប្រធានផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ដើម្បីមកពន្យល់នៅបន្ទប់សាលសវនាការនៅពេលព្រឹក ថ្ងៃពុធ ទី២៣ ខែឧសភា ឆ្នាំ២០១២", ២១ ឧសភា ២០១២។

[10] **E1/75.1** ប្រតិចារឹក, ២៣ ឧសភា ២០១២, ត្រង់ទំព័រ៩។

[11] **E11/86/1** របាយការណ៍វេជ្ជសាស្ត្រស្តីពីលោក អៀង សារី, ៣ កញ្ញា ២០១២ ត្រង់កថាខណ្ឌ៤១-៤២។

[12] **E1/125.1** ប្រតិចារឹក, ២១ កញ្ញា ២០១២ ត្រង់ទំព័រ១២។

[13] **E238/4** របាយការណ៍អ្នកជំនាញស្តីពី លោក អៀង សារី ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E238), ៦ វិច្ឆិកា ២០១២ ត្រង់កថាខណ្ឌទី៩ ("របាយការណ៍របស់អ្នកជំនាញ")។

[14] **E1/142.1** ប្រតិចារឹក, ៨ វិច្ឆិកា ២០១២ ត្រង់ទំព័រ១៦-១៧។

[15] **E238/4** របាយការណ៍អ្នកជំនាញ *កំណត់សម្គាល់លេខ១៣* ត្រង់កថាខណ្ឌទី២១។

៩- ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចជាលាយលក្ខណ៍មួយដែលសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[16]។ សេចក្ដីសម្រេចនេះក៏បានកត់សម្គាល់ផងដែរថា ភាពទន់ខ្សោយរបស់ជនជាប់ចោទបានធ្វើឲ្យមានការពន្យារពេលសវនាការមួយផ្នែក ឬទាំងមូលនៃថ្ងៃសវនាការចំនួន១២ថ្ងៃ[17] និងថាបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនៅតែជាកន្លែងដែលមេធាវីការពារក្ដី និងអង្គភាពពេទ្យរបស់ អ.វ.ត.ក អាចចេញចូលបានគ្រប់ពេល[18] និងថាហេតុដូច្នេះ គឺកន្លែងល្អបំផុតសម្រាប់តម្រូវការសុខភាពបច្ចុប្បន្នរបស់ អៀង សារី[19]។

១០- នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យ អៀង សារី ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនរបស់គាត់នៅក្រោមសាលសវនាការ ហើយបានបដិសេធសំណើរបស់មេធាវីការពារក្ដីស្នើសុំថត អៀង សារី ជាវីឌីអូ[20]។ សេចក្ដីសម្រេចនោះមានមូលដ្ឋាននៅលើរបាយការណ៍វេជ្ជសាស្ត្របានមកពីគ្រូពេទ្យព្យាបាល អៀង សារី ដែលបានស្នើថា ជនចាប់ចោទ "គួរត្រូវអនុញ្ញាតឲ្យតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការដែលអាចឲ្យវេជ្ជបណ្ឌិតមានលទ្ធភាពតាមឃ្លាំមើលពីស្ថានភាពផ្លូវកាយរបស់ អៀង សារី រួចជាស្រេច"[21]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ពីមតិស្របគ្នារបស់អ្នកជំនាញវេជ្ជសាស្ត្រនានា ដែលថាជនជាប់ចោទអាចមានលទ្ធភាពចូលរួមពីបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការបានងាយស្រួលជាងដោយមកពី "ស្ថានភាពរាងកាយ" "ការលំបាកផ្សេងៗ" រួមទាំងហានិភ័យនៃ "នៃការពន្យារពេលសវនាការ" ដោយគួបផ្សំជាមួយនឹងការនាំ អៀង សារី ចូលក្នុងសាលសវនាការ ហើយថាគ្រូពេទ្យរបស់ជនជាប់ចោទអាចនឹងតាមឃ្លាំមើលពីស្ថានភាពរបស់គាត់ ពីបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការបានល្អប្រសើរជាង[22]។ មេធាវីការពារក្ដីត្រូវបានអនុញ្ញាតឲ្យដាក់បុគ្គលិកម្នាក់ជាសមាជិក

[16] **E238/9** សេចក្ដីសម្រេចស្ដីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ២៦ វិច្ឆិកា ២០១២។

[17] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ៣៥។

[18] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌ ៣៦។

[19] *ដដែលដូចខាងលើ*។

[20] **E1/147.1** ប្រតិចារឹក, ៤ ធ្នូ ២០១២ ត្រង់ទំព័រ១៧-២០, ២៧-២៨។

[21] *ដដែលដូចមុន*, ទំព័រ១៨។

[22] *ដដែលដូចមុន*, ទំព័រ១៨-១៩, ២៧។

នៅក្នុងក្រុមរបស់ខ្លួន នៅក្នុងបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ ដើម្បីចាំប្រាប់ពីកង្វល់ផ្សេងៗ អំពីស្ថានភាពផ្លូវកាយរបស់ អៀង សារី ជូនដល់ គ្រូពេទ្យព្យាបាល[23]។ ក្រោយមក មេធាវីការពារក្តី បានធ្វើលើសពីវិសាលភាពនៃសិទ្ធិនោះ ហើយបានទទួលការដាស់តឿនពីកិរិយាមិនត្រឹមត្រូវពីអង្គជំនុំជម្រះសាលាដំបូង[24]។

១១- នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ មេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណាឡើងវិញពីសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២[25]។ សំណើមួយនេះ បណ្តាលឲ្យកើតមានជាសេចក្តីសម្រេចដែលរងការជំទាស់នេះ។

## III. បណ្តឹងសាទុក្ខនេះគឺស្តែងឲ្យឃើញថាមិនអាចទទួលយកបាន

### *ក. បណ្តឹងសាទុក្ខនេះគឺមិនអាចទទួលយកបានទេ តាមវិធាន១០៤(៤)(ខ)*

១២- នៅត្រង់កថាខណ្ឌទី២៣នៃបណ្តឹងសាទុក្ខមួយនេះ មេធាវីការពារក្តីបានលើកឡើងថាសេចក្តីសម្រេចដែលរងការជំទាស់នេះ ជារួម មិនត្រឹមតែមានបញ្ហាសម្បទាប៉ុណ្ណោះទេ ថែមទាំងមានបញ្ហាអំពីការតែងតាំងអ្នកជំនាញបន្ថែមទៀតផង ពាក់ព័ន្ធទៅនឹង "នីតិវិធីនៃការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី"។ ដូច្នេះ មេធាវីការពារក្តីបានអះអាងថាសេចក្តីសម្រេចដែលរងការជំទាស់នេះ "គឺជាការសម្រេចអំពីការឃុំខ្លួនពីព្រោះវាមានអានុភាពរក្សាទុក អៀង សារី ឲ្យស្ថិតនៅក្រោមការឃុំខ្លួន"[26] ហើយដូច្នេះ វាស្ថិតនៅក្រោមវិធាន ១០៤(៤)(ខ)។ មេធាវីការពារក្តីបានបន្ថែមនូវសទិសភាពមួយពីយុត្តិសាស្ត្រពីមុនរបស់អង្គបុរេជំនុំជម្រះ ដែលនៅក្នុងនោះ អង្គជំនុំជម្រះនេះបានចាត់ទុក "បញ្ហាថាតើឧបករណ៍ ឬវត្ថុ ដែលសមាជិកក្រុមមេធាវីការពារក្តីអាចយកចូល និងយកចេញ និងប្រើនៅក្នុង

---

[23] *ដដែលដូចមុន,* ទំព័រ២៧។

[24] **E254** អនុស្សរណៈជូនគ្រប់ភាគី "សេចក្តីសម្រេចដាក់សេចក្តីសន្និដ្ឋាន" ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ សូមមើលផងដែរ **E254/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី អៀង សារី សុំថតសោតទស្សន៍ និងវីដេអូ អៀង សារី នៅក្នុងបន្ទប់ឃុំឃាំងនៅខាងក្រោមសាលសវនាការ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ ត្រង់កថាខណ្ឌ១១ ("សេចក្តីសម្រេចពាក់ព័ន្ធនឹងការថតសោតទស្សន៍/វីដេអូ") ។

[25] **E238/11** សំណើរបស់ អៀង សារី សុំឲ្យពិចារណាឡើងវិញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចថា អៀង សារី មានសម្បទាចូលរួមសវនាការ និងបដិសេធសំណើសុំឲ្យមានការតែងតាំងអ្នកជំនាញបន្ថែមដើម្បីជួយកំណត់សម្បទា ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២។ [ការលើកឡើងពេញលេញ]។

[26] **E238/9/1/1** បណ្តឹងសាទុក្ខបច្ចុប្បន្ន, កំណត់សម្គាល់លេខ២ ត្រង់កថាខណ្ឌទី២៤ ។

មន្ទីរឃុំឃាំង ក្នុងពេលជួបជាមួយកូនក្តីរបស់ខ្លួន ក្នុងពេលឃុំខ្លួនបណ្តោះអាសន្ននោះ” ជាផ្នែកមួយនៃ “ទម្រង់ឃុំខ្លួនជនត្រូវចោទ”[27]។

១៣- សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ការបកស្រាយវិធាន១០៤(៤)(ខ)នេះ គឺមិនមានមូលដ្ឋានតាមផ្លូវច្បាប់ទាំងស្រុង។ ការអនុញ្ញាតឲ្យដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹង “សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយអនុលោមតាមវិធាន៨២”នោះ វិធាន១០៤(៤)(ខ) យោងទៅដល់សេចក្តីសម្រេចលើអង្គហេតុនានា ថាតើត្រូវឃុំខ្លួន ឬត្រូវដោះលែងជនជាប់ចោទ។ នៅក្នុងសេចក្តីសម្រេចបែបដូច្នេះដែល “ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន” ដែលអាស្រ័យលើខ្លឹមសារច្បាស់លាស់នៃវិធាន៨២ បាន “បើកផ្លូវឲ្យជនជាប់ចោទ ឬសហព្រះរាជអាជ្ញាប្តឹងសាទុក្ខបានតាមការសមស្រប”។ វិធាន៨២ មិនបានលើកឡើងពីបែបបទ ឬលក្ខខណ្ឌនៃការឃុំខ្លួននោះទេ ឬមួយក៏តាមពិតទៅ សេចក្តីសម្រេចនានាពាក់ព័ន្ធនឹងបែបបទ ក្នុងការចូលរួមនៅក្នុងសវនាការ ក្នុងករណី “មូលហេតុសុខភាព ឬកង្វល់ធ្ងន់ធ្ងរដទៃទៀត” ដែលត្រូវបានបញ្ញត្តិដោយវិធាន៨១(៥) មិនមែនដោយវិធាន៨២នោះឡើយ។ សេចក្តីសម្រេចលើសម្បទាក្នុងការចូលរួមសវនាការថាតើមាននៅក្នុងខ្លឹមសារវិធាន៨១(៥)ដែរ ឬផ្សេងពីនេះ គឺមិនអាចបកស្រាយដោយសមហេតុសមផលបានទេ ថាជា*សេចក្តីសម្រេចមួយស្តីពីការឃុំខ្លួន* ហើយជាការសមហេតុផល និងស្របតាមច្បាប់ ដែលថាវាខុសគ្នាពីសេចក្តីសម្រេចតាមវិធាន៨២ ដោយអាស្រ័យលើបណ្តឹងសាទុក្ខភ្លាមៗ តាមវិធាន១០៤(៤)(ខ)។

១៤- ការពឹងផ្អែករបស់មេធាវីការពារក្តីទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើកំណត់ហេតុកិច្ចប្រជុំជាមួយកូនក្តីរបស់ខ្លួន ក្នុងអំឡុងពេលនៃការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី គឺជាការយល់ច្រលំហើយ[28]។ បណ្តឹងឧទ្ធរណ៍នៅក្នុងករណីនោះគឺស្ថិតនៅក្រោមវិធាន៧៤(៣)(ច)នៃវិធានផ្ទៃក្នុង ដែលជាបទប្បញ្ញត្តិមួយផ្សេងគ្នា និងមានលក្ខណៈទូលំទូលាយជាងដែលអនុញ្ញាតឲ្យធ្វើបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលមុនសវនាការលើអង្គសេចក្តីប្រឆាំងនឹងដីកា ឬសេចក្តីសម្រេច “ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ”។ ផ្ទុយទៅវិញ វិធាន១០៤(៤)(ខ) គឺកម្រិតច្បាស់ជាង ដោយបានអនុញ្ញាតឲ្យធ្វើ

[27] **A371/2/12** ត្រង់កថាខណ្ឌទី១១ [សេចក្តីសម្រេចនេះត្រូវបានដកស្រង់ដោយពុំមានការយោងនៅក្នុងបណ្តឹងសាទុក្ខមួយនេះ]។
[28] *ដដែលដូចមុន*, ទំព័រ២៥។

បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹង"សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការអនុលោមតាមវិធាន៨២"។ ផលប្រយោជន៍តាមផ្លូវច្បាប់ដែលបានការពារ ដោយវិធាន៧៤(៣)(ច) ក្នុងអំឡុងពេលនៃការឃុំខ្លួនមុនសវនាការលើអង្គសេចក្តី គឺគ្រាន់តែជាផ្នែកមួយជាន់គ្នា ជាមួយនឹងផលប្រយោជន៍តាមផ្លូវច្បាប់ដែលបានការពារក្នុងអំឡុងពេលសវនាការ ដែលរួមមានទាំងសិទ្ធិរបស់សហជនជាប់ចោទក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីមួយដ៏ត្រឹមត្រូវ និងឆាប់រហ័សដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានពិចារណាត្រឹមត្រូវ នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់នេះ[29]។

១៥- សហព្រះរាជអាជ្ញាបានសង្កេតបន្ថែមទៀតថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបានលើកឡើងដោយមេធាវីការពារក្តី គឺកម្រិតត្រឹមតែបញ្ហាស្តីពីការនាំយកវត្ថុចូលទៅក្នុងមន្ទីរឃុំឃាំង ពីសំណាក់សមាជិកនានានៃក្រុមមេធាវីការពារក្តី និងការធ្វើកំណត់ហេតុ *កិច្ចប្រជុំទានារបស់ពួកគេ* ជាមួយនឹងជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំង។ ការណ៍នេះមិនគាំទ្រដល់ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍មួយពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទអនុលោមតាមវិធាន៨១[30]នោះឡើយ។ ទាក់ទងទៅនឹងបញ្ហាក្រោយនេះ អង្គជំនុំជម្រះតុលាការកំពូលពីមុនធ្លាប់ បានបដិសេធបណ្តឹងសាទុក្ខមួយរបស់ អៀង សារី អំពីបញ្ហាថាតើគេតម្រូវឲ្យមានវត្តមានរបស់ជនជាប់ចោទនៅក្នុងសាលសវនាការដែរ ឬទេ ដោយមានមូលដ្ឋានថាបណ្តឹងសាទុក្ខបែបដូច្នេះ មិនឋិតនៅក្រោម "អំណាចកម្រិត ចំពោះបណ្តឹងសាទុក្ខភ្លាមៗ យោងតាមវិធាន ១០៤(៤)នៃវិធានផ្ទៃក្នុង"នោះឡើយ[31]។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា បណ្តឹងសាទុក្ខមួយនេះត្រូវបដិសេធចោល ដោយមូលហេតុដូចគ្នា។

### *ខ. បណ្តឹងសាទុក្ខនេះគឺមិនអាចទទួលយកបានទេ តាមវិធាន១០៤(៤)(ឃ)*

១៦- នៅត្រង់កថាខណ្ឌទី២៤ មេធាវីការពារក្តីបានអះអាងថា "តាមរយៈសេចក្តីសម្រេចមួយចំនួនដែលមានទំនាក់ទំនងទៅវិញទៅមក (រួមទាំងសេចក្តីសម្រេចដែលរងការជំទាស់) អង្គជំនុំជម្រះសាលា

---

[29] **E238/9** សេចក្តីសម្រេចដែលរងការជំទាស់, កំណត់សម្គាល់*ខាងលើ* លេខ៦ ត្រង់ទំព័រ១៦។

[30] **E254/3** សេចក្តីសម្រេចពាក់ព័ន្ធនឹងការថតសោតទស្សន៍/វីដេអូ កំណត់សម្គាល់ខាងលើលេខ២៤ ត្រង់កថាខណ្ឌ១៣។

[31] **E130/4/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ, ១៣ មករា ២០១២។

ដំបូងបានជ្រៀតជ្រែកដោយចេតនា និងពិតប្រាកដ ជាបន្តបន្ទាប់ចូលក្នុងកិច្ចការរដ្ឋបាលតុលាការ"[32] ហើយថា សេចក្តីសម្រេចបែបដូច្នោះ គឺឋិតនៅក្រោមបណ្តឹងសាទុក្ខភ្លាមៗ តាមវិធាន ១០៤(៤)(ឃ)។ ដូច្នេះ មេធាវីការពារក្តីក៏បានសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តមាត្រា៣៥ ចំពោះ *អង្គជំនុំជម្រះសាលាដំបូងផ្ទាល់* - នៅក្នុងការអនុវត្តមុខងារតុលាការរបស់ខ្លួន - ដោយឈរលើមូលដ្ឋានមួយខុសដែលថា ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការដោយគ្រាន់តែអនុវត្តនូវមុខងារតុលាការដ៏ត្រឹមត្រូវ និងបានចេញនូវសេចក្តីសម្រេចដែលរងការជំទាស់នេះ។

១៧- ក្រុមមេធាវីការពារក្តីបានអះអាងថែមទៀតថា ដោយផ្អែកលើមូលដ្ឋាននៃការបកស្រាយរបស់ខ្លួនទៅលើ "សេចក្តីសម្រេចមួយចំនួនដែលមានការជាប់ទាក់ទងគ្នាទៅវិញទៅមក"៖

ក. ថា "អង្គជំនុំជម្រះសាលាដំបូងបានព្យាយាម*តាមគ្រប់*វិធី ដែលអាចធ្វើទៅបាន" ដើម្បីធ្វើជាខែលការពារខ្លួនឲ្យរួចផុតពីព័ត៌មាន*ណាមួយ* ដែលនឹងបំបាត់ចោលដោយតម្លាភាព និងដោយពិតប្រាកដនូវរឿងព្រេងនិទាន ដែលថា "ឥឡូវនេះ អៀង សារី មានសមត្ថភាពអាចចូលរួមនៅក្នុងដំណើរការនីតិវិធីជំនុំជម្រះក្តីបានប្រកបដោយអត្ថន័យ"[33] ។ និង

ខ. ថា អង្គជំនុំជម្រះសាលាដំបូង "បានចាត់ការបន្ថែមទៀត តាមដែលអាចធ្វើទៅបានដើម្បីឲ្យប្រាកដថា មានកំណត់ហេតុតិចតួច ឬក៏គ្មានទាល់តែសោះ អំពីកំណត់ហេតុស្តីពីស្ថានភាពបច្ចុប្បន្នរបស់ អៀង សារី"[34] ។

១៨- សហព្រះរាជអាជ្ញា មានការបារម្ភ ពីដើមដំបូងមកថា ការវាយប្រហារដែលគ្មានការអៀនខ្មាស់នឹងដែលការវាយប្រហារទាំងអស់ដែលមិនមានការចង្អុលបង្ហាញភ័ស្តុតាងទៅលើសុច្ចរិតភាព របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង គឺជាផ្នែកនៃយុទ្ធសាស្ត្រនៃការធ្វើឲ្យផ្អាកដំណើរការដែលមិនត្រឹមត្រូវ

[32] **E238/9/2/1** បណ្តឹងសាទុក្ខ កំណត់សម្គាល់ខាងលើលេខ២ ត្រង់កថាខណ្ឌ២៤។

[33] ឯកសារលេខ **E238/9/2/1** *ដូចគ្នានឹងខាងលើកន្លែងដដែល*។

[34] ឯកសារលេខ **E238/9/2/1** *ដូចគ្នានឹងខាងលើកន្លែងដដែល*។

និងមិនលាតត្រដាងឲ្យឃើញ ដើម្បីធ្វើឲ្យរដ្ឋបាលរបស់តុលាការនៅចំពោះមុខអង្គជំនុំជម្រះមិនឲ្យអាប់ឱនកិត្តិយស។

១៩- សហព្រះរាជអាជ្ញាជូនជាយោបល់ថា ជាក់ស្តែងគឺគ្មានមូលដ្ឋានខាងអង្គច្បាប់ សម្រាប់យកមកធ្វើជាទឡ្ហីករណ៍សម្រាប់ប្តឹងសាទុក្ខភ្លាមៗ លើវិធាន១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុងនោះឡើយ។ វិធាននេះបើកឲ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗទៅអង្គជំនុំជម្រះតុលាការកំពូលបាន ប្រឆាំងនឹង "សេចក្តីសម្រេចនានាស្តីពីការជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការតាមវិធាន៣៥(៦)"។ ដូចដែលអង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនហើយថា បណ្តឹងសាទុក្ខបែបនេះអាចឲ្យទទួលយកបាន" តែនៅក្នុងករណីសំណើដែលជាដើមចម អាចត្រូវបានកំណត់ចរិតលក្ខណៈ យ៉ាងហោចណាស់ក៏មួយផ្នែកថាជាសំណើសុំបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុង"[35]។ ដោយហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា បណ្តឹងសាទុក្ខណាមួយទៅនឹងសេចក្តីសម្រេចបដិសេធញត្តិស្នើសុំប្តឹងដឹតចិត្តលោកស្រីចៅក្រម Silvia Cartwright ដែល "សំណើនោះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានលើកយោង ដោយមានការកម្រិតទៅលើវិធាន៣៥នៃវិធានផ្ទៃក្នុង" និង "បានស្វែងរកសុំបំពេញកិច្ចស៊ើបសួរមួយ ដោយអនុលោមតាមវិធាន៣៥(២)នៃវិធានផ្ទៃក្នុង" អំពីការចោទប្រកាន់ថាមានការជួបប្រជុំគ្នា *ជាមួយភាគីតែម្ខាង*[36]។

២០- ផ្ទុយទៅវិញ ក្នុងករណីនេះ មេធាវីការពារក្តីមិនបានធ្វើសំណើសុំទៅអង្គជំនុំជម្រះសាលាដំបូង តាមវិធាន៣៥ទាល់តែសោះ។ សេចក្តីសន្និដ្ឋានផ្ទាល់មាត់ដែលបានធ្វើឡើងដោយមេធាវី Michael Karnavas កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២នោះ មិនបានលើកឡើងយោងដោយចំៗ ឬមិនច្បាស់លាស់អនុលោមតាមវិធាន៣៥ ឬផលប្រយោជន៍ស្របច្បាប់ដែលត្រូវបានការពារតាមរយៈវិធាននេះនោះឡើយ[37]។ នៅពេលនោះ មេធាវីការពារក្តីគ្រាន់តែបានធ្វើការគូសបញ្ជាក់អំពី "ភារកិច្ច និងការ

[35] ឯកសារលេខ **E137/5/1/3** សេចក្តីសម្រេចបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងសុំប្តឹងដឹតចិត្តលោកស្រីចៅក្រម Cartwright, ចុះថ្ងៃទី១៧ មេសា ២០១២, ត្រង់កថាខណ្ឌទី១១ ("សេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងដិតចិត្ត")។

[36] *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១២ និងទី១៦។

[37] ឯកសារលេខ **E1/147.1** ប្រតិចា◌ិរឹក កំណត់សម្គាល់ខាងលើលេខ២០, ត្រង់កថាខណ្ឌពីទី ១២-១៥។

ទទួលខុសត្រូវរបស់សហមេធាវីការពារក្តី ក្នុងការការពារសិទ្ធិរបស់កូនក្តីរបស់ខ្លួនតែប៉ុណ្ណោះ”[38]។ ស្រដៀងគ្នានេះដែរ ទាំងនៅក្នុងសំណើចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ និងទាំងនៅក្នុងសេចក្តីសន្និដ្ឋានពាក់ព័ន្ធផ្សេងៗទៀតមិនបានលើកយោងដោយចំៗ ឬមិនច្បាស់លាស់ទៅលើវិធាន៣៥ ឬផលប្រយោជន៍ស្របច្បាប់ដែលបានការពារដោយវិធាននេះ។ គឺជាការមិនត្រឹមត្រូវឡើយដែលមេធាវីការពារក្តីស្វែងរកសុំឲ្យធ្វើការពិនិត្យឡើងវិញ ទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយបន្ទាប់មកឲ្យធ្វើការបកស្រាយលើការបដិសេធណាមួយតាមបំណងចង់បានរបស់ពួកគេ ដែលថាជាការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។ ផ្ទុយទៅវិញ គឺការអះអាងរបស់មេធាវីការពារក្តីដែលធ្វើឲ្យមានការជំទាស់ទៅនឹងកិច្ចការរដ្ឋបាលល្អរបស់តុលាការ។ ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាជូនជាមតិថា សំណើសុំជាដើមអាទិ៍ដែលបណ្តាលឲ្យសេចក្តីសម្រេចដែលរងការជំទាស់នេះគឺមិនមែនជាសំណើដែលអនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុងឡើយ។

២១- លើសពីនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បណ្តឹងសាទុក្ខណាមួយដែលបានធ្វើឡើងដោយអនុលោមតាមវិធាន១០៤(៤)(ឃ)នៃវិធានផ្ទៃក្នុង មិនគួរបង្ហាញអំពី “ការចោទប្រកាន់នានាដែលជាក់ស្តែងវិធាន៣៥នៃវិធានផ្ទៃក្នុង មិនអាចអនុវត្តបានលើការចោទប្រកាន់ទាំងនោះឡើយ”[39]។ ដូចដែលអង្គជំនុំជម្រះនេះបានសម្រេចបដិសេធបណ្តឹងសាទុក្ខពីលើកមុនរបស់មេធាវីការពារក្តី អៀង សារី ពាក់ព័ន្ធអំពីថាតើគាត់គួរត្រូវបានតម្រូវឲ្យមានវត្តមាននៅក្នុងសាលសវនាការដែរ ឬអត់៖

> *គ្មានកំហុសអង្គច្បាប់ ឬអង្គហេតុ និងគ្មានការរំលោភឆន្ទានុសិទ្ធិអង្គជំនុំជម្រះសាលាដំបូងណាមួយទេ ដែលអាចបង្កើតជាការជ្រៀតជ្រែកដោយដឹង និងមានចេតនា ទៅលើកិច្ចការរដ្ឋបាលតុលាការ តាមអត្ថន័យនៃវិធាន៣៥នៃវិធានផ្ទៃក្នុងឡើយ*[40] ។

បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទៀតថា “ការយកវិធាន៣៥នៃវិធានផ្ទៃក្នុង មកអនុវត្តចំពោះចំណាត់ការរបស់តុលាការ គឺត្រូវបានរឹតត្បិតយ៉ាងខ្លាំង”[41] ហើយហេតុដូច

[38] *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់ទំព័រ១៣។ សូមមើលផងដែរឯកសារលេខ E238/9/1/1 បណ្តឹងសាទុក្ខបច្ចុប្បន្ន កំណត់សម្គាល់ខាងលើលេខ២ ត្រង់កថាខណ្ឌទី១៦។

[39] ឯកសារលេខ E137/5/1/3 សេចក្តីសម្រេចបណ្តឹងជិតចិត្ត កំណត់សម្គាល់ខាងលើលេខ៣៥, ត្រង់កថាខណ្ឌទី១២។

[40] ឯកសារលេខ E130/4/3 សេចក្តីសម្រេចវត្តមាននៅក្នុងសាលសវនាការ, កំណត់សម្គាល់ខាងលើលេខ៣០, ត្រង់កថាខណ្ឌ២។

[41] ឯកសារលេខ E137/5/1/3 សេចក្តីសម្រេចលើបណ្តឹងជិតចិត្ត កំណត់សម្គាល់ខាងលើលេខ៣៥ ត្រង់កថាខណ្ឌ១៣។

នេះ "ការសម្រេចដោយខុសឆ្គងរបស់តុលាការ គឺមិនគ្រប់គ្រាន់តាមផ្លូវច្បាប់ទេ ដើម្បីបំពេញបាននូវបទដ្ឋាន ស្របតាមវិធាន៣៥ឡើយ"[42]។

២២- សេចក្តីសម្រេចដែលរងការជំទាស់ មិនបានយោងទៅលើវិធាន៣៥នៃវិធានផ្ទៃក្នុងឡើយ មិនបានសំដៅទៅលើទស្សនទានស្តីពីការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ឬមិនសំដៅទៅលើបញ្ហាណាដែលយល់ដឹងដោយវិញ្ញាណណាមួយនោះឡើយ[43]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាជូនយោបល់ថា គ្មានមូលដ្ឋានខាងអង្គច្បាប់ណាដែលគួរឱ្យជឿបាន សម្រាប់បកស្រាយលើសេចក្តីសម្រេចដែលរងការជំទាស់ថាជា "សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ នៅក្រោមវិធាន៣៥(៦)នៃវិធានផ្ទៃក្នុងនោះឡើយ"[44]។

### *គ. ផ្នែកដែលអាចដំណើការបាននៃសេចក្តីសម្រេចដែលរងការជំទាស់ មិនបានផ្តល់នូវសិទ្ធិតែមួយគត់ក្នុងការប្តឹងសាទុក្ខ ក្រៅពីវិសាលភាពនៃវិធាន១០៤ទេ*

២៣- សហព្រះរាជអាជ្ញាបានសង្កេតឃើញថា ផ្នែកដែលអាចដំណើរការបាននៃសេចក្តីសម្រេចដែលរងការជំទាស់ រួមមាន កំណត់សម្គាល់មួយពីអង្គជំនុំជម្រះសាលដំបូងដែលថា "បណ្តឹងសាទុក្ខភ្លាមៗណាមួយ"ប្រឆាំងនឹងសេចក្តីសម្រេចដែរងការជំទាស់ "គឺមិនអាចផ្អាកដល់ដំណើរការនីតិវិធីសវនាការ"នៅចំពោះមុខអង្គជំនុំជម្រះនេះបានឡើយ[45]។ បណ្តឹងសាទុក្ខភ្លាមមិនបានលើកឡើងនូវទឡ្ហីករណ៍ទេនៅក្នុងចំណុចនេះ។ ដើម្បីជាប្រយោជន៍ដល់ការបញ្ចប់ករណីនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថាការលើកទឡ្ហីករណ៍នេះមិនអាចផ្តល់សិទ្ធិ *ពិសេសតែមួយគត់* ដល់មេធាវីការពារក្តីក្នុងការដាក់បណ្តឹងសាទុក្ខនេះ ឲ្យហួសពីវិសាលភាពនៃវិធាន១០៤នៃវិធានផ្ទៃក្នុងបានឡើយ ដែលបានចែងយ៉ាងល្អិតល្អន់អំពីហេតុផលដែលអាចទទួលយកបាន ចំពោះបណ្តឹងសាទុក្ខបែបនេះ។ ការលើកឡើងបែបនេះអាចត្រូវបានបកស្រាយដោយត្រឹមត្រូវថា ជាកំណត់សម្គាល់ចំពោះមេធាវី

---

[42] *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១៣។ ការដកស្រង់សំដីពីឯកសារលេខ **E130/4/3** សេចក្តីសម្រេចវត្តមាននៅក្នុងសាលសវនាការ, កំណត់សម្គាល់ខាងលើលេខ៣០ ត្រង់កថាខណ្ឌ២។

[43] ឯកសារលេខ **E1/147.1** ប្រតិចារឹក, កំណត់សម្គាល់ខាងលើលេខ២០ ត្រង់ទំព័រពី១៧-១៩ និងពី ២៧-២៨។

[44] វិធាន ១០៤(៤)(ឃ)នៃវិធានផ្ទៃក្នុង។

[45] ឯកសារលេខ **E238/9/2/1** សេចក្តីសម្រេចដែលរងការជំទាស់, កំណត់សំគាល់លេខ៦ ត្រង់កថាខណ្ឌ១៦។

ការពារក្តី ដែលប្រាស់ចាកពីការប្រុងប្រយ័ត្ន និងបន្ថយដល់អំណាចពិសេសរបស់អង្គជំនុំជម្រះក្នុងការសម្រេចថាតើ បណ្តឹងសាទុក្ខភ្លាមៗមួយ ជាការពិតត្រូវមានដែរ ឬទេ នៅក្នុងកាលៈទេសៈបែបនេះ។

២៤- សហព្រះរាជអាជ្ញាប្រកាន់ជំហរថា បញ្ហាអង្គច្បាប់ពាក់ព័ន្ធនានាត្រូវបានរៀបរាប់ដោយសង្ខេបក្នុងសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ ហើយមិនតម្រូវឲ្យមានចម្លើយតបបន្ថែម ឬសវនាការផ្ទាល់មាត់ ឬសាធារណៈទេ ក្នុងការសម្រេចបណ្តឹងសាទុក្ខនេះឲ្យបានត្រឹមត្រូវ និងឆាប់រហ័ស។

## IV. **សេចក្តីសន្និដ្ឋាន**

២៥- អាស្រ័យហេតុផលដូចបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះ៖

ក. ជូនដំណឹងដល់ភាគីថានឹងមិនចាំបាច់ធ្វើចម្លើយតបទេ។

ខ. សម្រេចថា បណ្តឹងសាទុក្ខនេះទាំងមូលមិនអាចទទួលយកបានទេ។

គ. បដិសេធសំណើរបស់សហមេធាវីការពារក្តីដែលស្នើសុំឲ្យធ្វើសវនាការដោយផ្ទាល់មាត់ជាសាធារណៈ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក William SMITH** សហព្រះរាជអាជ្ញារង | | [signature] |